**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ៣៣២
ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៨
**សាលដីកា**
លេខ: ២៤០
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ................. ជាចៅក្រម
៣-លោក ................. ជាចៅក្រមរបាយការណ៍
៤-លោក ................. ជាចៅក្រម
៥-លោក ................. ជាចៅក្រម
៦-លោក ................. ជាចៅក្រម
៧-លោក ................. ជាចៅក្រម
៨-លោក ................. ជាចៅក្រម
៩-លោក ................. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-លោកស្រី ...............

**<u>តំណាងមហាអយ្យការ</u>**
-លោក ............. ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៤០៤ ចុះថ្ងៃទី១៦-០៧-១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤០ ចុះថ្ងៃទី២៧-១០-៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ បជ ភេទប្រុស អាយុ៤៤ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ីពាណិជ្ជករ ទីលំនៅសព្វថ្ងៃ ក្រុមទី៥ មណ្ឌល៣ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះគឹម ទូន "ស" ម្តាយឈ្មោះ ទឹម សុខ "រ" ដែលមានលោក ............ ជាមេធាវី ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ លហឡ ភេទប្រុស អាយុ៤៥ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ីពាណិជ្ជករ ទីលំនៅសព្វថ្ងៃ ក្រុមទី៦ មណ្ឌល២ សង្កាត់២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានលោក ......... ជាមេធាវី ។

***<u>កម្មវត្ថុបណ្តឹង:</u>*** ប្តឹងទាមទារដីទំហំ ៦ហិចតា ៩០អា ៤៧សង់ទីអា ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៣៣ ចុះថ្ងៃទី៣១-០៨-៩៨ របស់លោក បជប្តឹងមិនសុខចិត្ត ពីសាលដីកាលេខ៤០៤ ចុះថ្ងៃទី១៦-១៧-៩៨ របស់សាលាឧទ្ធរណ៍លើចំណុចនៃសេចក្តីសម្រេច ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៣២ ចុះថ្ងៃទី២៧-១០-១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៧-០៥-៩៦ របស់ឈ្មោះជា សារិន តំណាងឱ្យឈ្មោះលហឡ ជាដើមចោទប្តឹងសុំទាមទារដីទំហំ៦ហិចតា៩០អា៤៧សង្ទីអា ពីលោក បជដោយសំអាងហេតុថា លោក បជបានរំលោភយកដីពីលោក លីម ហ៊ុយឡេង ដោយបានដាំដំណាំ និងលួចធ្វើប្លង់និងសុំឱ្យលោក បជផ្អាកសកម្មភាពដាំដុះដែលបង្កឱ្យប៉ះពាល់កិច្ចការរបស់តុលាការកំពុងដោះស្រាយ ។

បានឃើញសាលក្រមលេខ០៨ ចុះថ្ងៃទី៣១-០១-៩៧ របស់តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹង របស់ដើមចោទ ចុះថ្ងៃទី០៧-០៥-៩៦ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់ នឹងគតិច្បាប់ ។

២- ទទួលស្គាល់កិច្ចសន្យាលក់ដូរដី របស់ឈ្មោះសំ សារិន ហៅសឿទូច និងហាក់ផាត ឱ្យ លោក បជទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

៣-ចាត់ទុកជាមោឃៈនូវកិច្ចសន្យាលក់ដីលើកទី១ចុះថ្ងៃទី០៦-០៧-៩៣ របស់ឈ្មោះ ហាច់ រិទ្ធីវុធ ហៅ ថាច់ រិទ្ធីវុធ ជាមួយឈ្មោះ ឆេខា និង ជិន វ៉ាន់ថន កិច្ចសន្យាលើកទី២ ចុះថ្ងៃទី១៥-០៧-៩៣ និងលើកទី៣ ចុះថ្ងៃទី១៥-០៧-៩៣ របស់ឈ្មោះ សឿ ទូច ពេជ្រ ផាត ហៅ ហាក់ ផាត ថាច់ រិទ្ធីវុធ និងណុប វ៉ុន ជាមួយឈ្មោះ ឆេខា និង ជិនវ៉ាន់ថន ។

៤-ទទួលស្គាល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខC10132ចុះថ្ងៃទី៣០-០៣-៩៣ ទំហំដី៥ហិកតាមានឈ្មោះ ចាប គឹមលាង និងបជជាម្ចាស់ និងលេខ**C10133** ចុះថ្ងៃទី៣០-០៣-៩៣ ទំហំ ៤ហិកតា ៧២អា ៧១សង្ទីអា មានទីតាំងស្ថិតនៅ ភូមិគគី ឃុំបិតត្រាំង ស្រុកព្រៃនប់ ក្រុងព្រះសីហនុ ចេញដោយការិយាល័យភូមិបាលស្រុកព្រៃនប់ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៥-កែតម្រូវប័ណ្ណសំគាល់សិទ្ធិ កាន់កាប់ប្រើប្រាស់ដីធ្លីចំនួន០៦ ចេញដោយការិយាល័យភូមិបាលស្រុកព្រៃនប់ ដោយកាត់ចេញនូវទំហំផ្ទៃដីដូចខាងក្រោមនេះ

ក-ប័ណ្ណសំគាល់សិទ្ធិលេខ**C10275** ចុះថ្ងៃទី០៥-១០-៩៣ មានឈ្មោះ ឡ សុវណ្ណ ជាម្ចាស់ ផ្ទេរពីប័ណ្ណលេខ**C10158** ចុះថ្ងៃទី១២-០៧-៩៣ មានឈ្មោះ លហឡ និងនាង អ៊ុង ថាវី ជាម្ចាស់កាត់ចេញពីទំហំផ្ទៃដីចំនួន១៦.៩៨៨ ម$^{២}$ ។

ខ- ប័ណ្ណសំគាល់សិទ្ធិលេខ**C10276** ចុះថ្ងៃទី០៥-១០-៩៣ មានឈ្មោះ ឡូ សុវណ្ណ ជាម្ចាស់ ផ្ទេរពីប័ណ្ណលេខ**C10160** ចុះថ្ងៃទី១២-០៧-៩៣ មានឈ្មោះ អ៊ុង ថាវី និង លហាឡ ជាម្ចាស់ កាត់ចេញទំហំផ្ទៃដីចំនួន១៥.៣៨៧ ម$^{២}$ ។

គ-ប័ណ្ណសំគាល់សិទ្ធិលេខ**C10280**ចុះថ្ងៃទី០៥-១០-៩៣មានឡូហ៊ុយហូ ជាម្ចាស់ ផ្ទេរពីប័ណ្ណលេខ **C10157** ចុះថ្ងៃទី១២-០៧-៩៣ មានឈ្មោះ ឡាំង អ៊ឹង ជាម្ចាស់ កាត់ចេញទំហំផ្ទៃដីចំនួន១៦.៧៥៥ម$^{២}$។

ឃ-ប័ណ្ណសំគាល់សិទ្ធិលេខ**C10274**ចុះថ្ងៃទី០៥-១០-៩៣មានឈ្មោះឡូទីម៉ីញជាម្ចាស់ផ្ទេរពីប័ណ្ណលេខ**C10159** ចុះថ្ងៃទី១២-០៧-៩៣ មានឈ្មោះលហាឡ និងនាងអ៊ឹង ថាវី ជាម្ចាស់ កាត់ចេញពីទំហំផ្ទៃដីចំនួន ១៨.៣៣៧ ម$^{២}$ ។

ង-បណ្ណំសំគាល់សិទ្ធិលេខC10278ចុះថ្ងៃទី០៥-១០-៩៣មានឈ្មោះឡូវន្នីជាម្ចាស់ផ្ទេរពីប័ណ្ណលេខ C1 0154 ចុះថ្ងៃទី១២-០៧-៩៣ មានឈ្មោះ ឃូ ងួន ជាម្ចាស់ កាត់ចេញទំហំផ្ទៃដី១,៨៨៥ម$^{២}$

ច- ប័ណ្ណសម្គាល់សិទ្ធិលេខC1 0281 ចុះថ្ងៃទី០៥-១០-៩៣ មានឈ្មោះ ឡូ សុគន្ធ ជាម្ចាស់ ពីប័ណ្ណលេខC1 0156 ចុះថ្ងៃទី១២-០៧-៩៣ មានឈ្មោះ លឹម ហៀង ជាម្ចាស់ កាត់ចេញទំហំផ្ទៃដីចំនួន ២.៦២៦ម$^{២}$ ។

៦-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១.៨០០រៀល វង្វាន់ក្រឡាបញ្ជីកាន់ ហិបប្រាក់២០០រៀល និងវង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០៛ សរុបរួម ៧.០០០រៀល ប្រាក់នេះត្រូវកាត់យកពីប្រាក់៧.០០០រៀល ដែលដើមចោទ បានបង់រួចហើយ កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១% លើតម្លៃដីទំហំ៧១.៩៧៨ម$^{២}$ ដែលត្រូវបង់ចូលថវិការដ្ឋចំនួន៨០% និងបានជាវង្វាន់ក្រឡាបញ្ជី ទូទាំងកម្ពុជា២០% ពន្ធនេះតម្រូវឱ្យលោក បជបង់ជាមុន ទើបបង្គាប់ឱ្យលោក......... តំណាងលោក លហាឡ សងទៅលោក បជជាក្រោយ ។

សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់លោក......... តំណាងឱ្យលោក លហាឡ ចុះថ្ងៃទី ៣១-០១-៩៧ ប្តឹងមិនសុខចិត្តលើសេចក្តីសម្រេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីកា របស់សាលាឧទ្ធរណ៍លេខ៣៤៣ ចុះថ្ងៃទី១៨-០៦-៩៧ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-០១-១៩៩៧ របស់ឈ្មោះ......... ជាមេធាវី របស់ឈ្មោះ លហាឡ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៨ ចុះថ្ងៃទី ៣១-០១-១៩៩៧ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការដដែល ។

៣-រឹបអូសយកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួច គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការចំនួន៥០០០រៀល សរុបចំនួន ១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបញ្ជឹងសាទុក្ខរបស់លោក......... ជាមេធាវីរបស់លោក លហាឡ ចុះថ្ងៃទី២០-០៦-៩៧ ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលដីកាទាំងមូល ។

បានឃើញសាលដីកា របស់តុលាការកំពូលលេខ១៥៣ ចុះថ្ងៃទី២៨-០៨-៩៧ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ២១៨ ចុះថ្ងៃទី២០ខែមិថុនាឆ្នាំ១៩៩៧របស់លោក......... តំណាងឱ្យលោក លហាឡ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៣៤៣ ចុះថ្ងៃទី១៩ ខែមិថុនាឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៩០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលភាគីលោក លហាឡ បានបង់រួចហើយគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែ ប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យលោក បជសងប្រជាក់ចំនួន១៩០០០រៀល នេះជូនទៅលោក លហាឡវិញ ។

៥-សាលដីកានេះ ប្រកាសនាពេលសវនាការ ជាសាធារណៈ នៅថ្ងៃទី២៨ ខែសីហាឆ្នាំ១៩៩៧ ។

បានឃើញសាលដីការបៀប របស់សាលាឧទ្ធរណ៍លេខ៣២ ចុះថ្ងៃទី០៩-០៧-៩៨ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

-សម្រេចចាត់របៀប បញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ៨០ ចុះថ្ងៃទី១២-០៩-៩៧ របស់តុលាការក្រុងព្រះសីហនុ ចូលក្នុងសំណុំរឿងលេខ៤០ ចុះថ្ងៃទី២៧-១០-៩៧ របស់សាលាឧទ្ធរណ៍ ។

បានឃើញសាលដីកា របស់សាលាឧទ្ធរណ៍លេខ៤០៤ ចុះថ្ងៃទី១៦-០៧-៩៨ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះ ជាថ្មីសំណុំរឿងលេខ៣០២ ចុះថ្ងៃទី១២-០៥-៩៧ របស់សាលាឧទ្ធរណ៍តាមអំណាចសាលដីកាលេខ១៥៣ ចុះថ្ងៃទី២៨-០៨-៩៧ របស់តុលាការកំពូល ។

២-មិនទទួលស្គាល់កិច្ចសន្យា លក់ទិញដី គ្មានថ្ងៃបរិច្ឆេទ រវាងលោក បជនិង លោកសំសារិន ថាជាកិច្ចសន្យា លក់ ទិញ ដីទំនាស់ឡើយ ។ តាមមាត្រា ៣២ នៃក្រឹត្យច្បាប់លេខ៣៨ ។

៣-ទទួលស្គាល់កិច្ចសន្យា លក់ទិញដី ចុះថ្ងៃទី០៦-០៧-៩៣. ចុះថ្ងៃទី១៥-០៧-៩៣ និងចុះថ្ងៃទី២៥-០៧-៩៣ រវាងលោកសឿ ទូច (សំសារិន) ពេជ្រ សុផាត ថាច់រិទ្ធីវុធ និងណុប វ៉ុន ជាមួយ លោក ឆេខា និង ជិនវ៉ាន់ថន ជាកិច្ចសន្យមានសុពលភាពត្រឹមត្រូវ ទាំងលើដីទំនាស់ និង ទាំងលើដីគ្មាន ទំនាស់ ។ តាមមាត្រាទី៣ នៃក្រិត្យច្បាប់លេខ៣៨ ។

៤-បដិសេធប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខC10133 ដែលមានម្ចាស់ឈ្មោះ បជនិងនាងចាបគឹមលាង ចុះថ្ងៃទី៣០-០៣-៩៣ និងបណ្ណ័សម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី លេខ C10132 ដែលមានម្ចាស់ឈ្មោះ ចាបគឹមលាង និងឈ្មោះ បជចុះថ្ងៃទី ៣០-០៣-៩៣ ចុះហត្ថលេខាដោយ ប្រធានសុរិយោដីក្រុងព្រះសីហនុ ចោលជាអសារបង់ ដោយផ្ទុយនឹងមាត្រា១១២ចំណុចទី៦ នៃច្បាប់ភូមិបាល ។

៥-ទទួលស្សល់

ក- បណ្ណ័សម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខC10158 ចុះថ្ងៃទី១២-០៧-៩៣កាន់កាប់ដោយលោក លហឡ ។

ខ- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លីលេខC10160 ចុះថ្ងៃទី១២-០៧-៩៣ កាន់កាប់ដោយអ្នកស្រី អ៊ុង ថារី។

គ- ប័ណ្ណសម្គាល់សិទ្ធិកាន់កប់ ប្រើប្រាស់ដីធ្លីលេខC1 0157 ចុះថ្លៃទី១២-០៧-៩៣ កាន់កាប់ដោយកញ្ញា ឡាវ អ៊ុង ។

ឃ-បណ្ណ័សម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខC10159 ចុះថ្ងៃទី១២-០៧-៩៣ កាន់កាប់ដោយលោក លហឡ ។

ង-  ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់  ប្រើប្រាស់ដីធ្លីលេខC10154ចុះថ្ងៃទី១២-០៧-៩៣កាន់កាប់C10133 របស់ឈ្មោះ បជទាំងស្រុង តំណាងមហាអយ្យការសំណូមពរ ក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ តាមអង្គហេតុ និងសម្រេចតាមអង្គច្បាប់ តាមការគួរ ។

បានស្តាប់ចម្លើយរបស់លោកបជជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះថា ខ្លួនឈ្មោះ បជដីនេះ ខ្លួនទិញតាំងពី ថ្ងៃទី២៨-១០-៩២ ដោយអ្នកទាំង៥ មានឈ្មោះ សំសារិន ហៅ សៀ ទូច ហាក់ ផាត,ណុប វន់ ថាច់រិទ្ធីវុធ និង សៀទួន បានធ្វើបេងពទ្ធ័ជុំវិញ ដោយយកដើមដូង និងដើមអាកាស្យា ធ្វើជាព្រំប្រទល់ ទើបខ្លួនប្រគល់លុយឱ្យ។ ពេលខ្លួនទិញហើយ ទើបសុរិយោដីចុះវាស់វែង ធ្វើប័ណ្ណកម្មសិទ្ធិដែលមានប្លង់២ប្លង់ទី១ ជារបស់ប្រពន្ធខ្លួន ដែលមានលេខសម្គាល់C10132 ចុះថ្ងៃទី៣០-០៣-៩៣ និងមួយទៀត ជារបស់ខ្លួនដែលមានលេខសំគាល់C10133ចុះថ្ងៃទី៣០-០៣-៩៣ ហើយខ្លួនបានកាន់កាប់រហូតដល់សព្វថ្ងៃនេះ ។ នៅខែ៧,៨ ឆ្នាំ៩៣មានបាតុភាពមិនស្រួលខ្លួនប្តឹងទៅស្រុក ពេលនោះស្រុកចុះមកពិនិត្យដល់ កន្លែងកើតហេតុ ឃើញមានប្លង់ត្រួតលើប្លង់របស់ខ្លួន ពេលនោះភូមិបាលស្រុក ចេញសេចក្តីកែតំម្រូវមួយលុបចោល ប័ណ្ណកម្មសិទ្ធិរបស់លហឡចោល ។ ខ្លួននិងដើមចោទគ្មានអ្វីទាក់ទងគ្នាទេ តែគាត់ប្តឹងខ្លួនថាខ្លួនរំលោភយកដីគាត់ តែតាមពិតប័ណ្ណកម្មសិទ្ធិខ្លួន ចុះថ្ងៃទី៣០-០៣-៩៣ គាត់ទិញដីនៅថ្ងៃទី២៥-០៧-៩៣ មានទំហំ២៤ហិកតា តែតាមពិតដីខ្លួនមានតែ៤ហិកតាជាងប៉ុណ្ណោះ ។ បានជាលិខិតទិញមានចុះហត្ថលេខាតែពីរនាក់ព្រោះ អ្នកទាំងពីរមានសិទ្ធិលើបីនាក់នោះ ព្រោះត្រូវជា មា និងក្មួយ ។

ខ្លួនទិញដីនេះគ្មានបង្កាន់ដៃទេ  គឺទិញតាមរូបភាពឱ្យរដ្ឋអំណាចនិងភូមិបាលស្រុកចុះវាស់វែងធ្វើប្លង់ ព្រោះដីនោះជាដីបង្កបង្កើនផល ដែលសម្តេចប្រគល់ឱ្យ ។

បានជាប្លង់របស់លហឡ មានច្រើនខុសៗគ្នា ព្រោះគាត់ធ្វើមួយយកប្តឹងខ្លួន ដល់ពេល ខុសពីទំហំដីពិតប្រាកដ គាត់ចោល ហើយធ្វើថ្មីទៀត ដោយឃុបឃិតជាមួយសុរិយោដី ម្យ៉ាងទៀត ដោយគាត់ចេះ តែចង្អុល គ្មានព្រំប្រទល់ច្បាស់លាស់ ។ ដីនោះ គ្មានរបងខណ្ឌ័ចំកណ្តាលទេ ។

ក្រឡាបញ្ជី អានសារណា របស់លោក លហឡ ។

បានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីចុងចម្លើយ នៅពេលជំនុំជំរះថា ៖

កូនក្តីខ្លួនទិញដីមានបង្កាន់ដៃ ទើបកូនក្តីខ្លួនឱ្យប្រាក់កក់ ។ ក្នុងសារណារបស់លោក......... ថា ឆេខា និង ជិនវ៉ាន់ថន ជាតំណាងរបស់ លហឡ តែអ្នកទាំងពីរនេះជាម្ចាស់ដី និងជាសាក្សីក្នុង សំណុំរឿង ។ នៅថ្ងៃទី២៨-១០-៩២ អ្នកទាំង៥ បានលក់ដី២ពយឱ្យកូនក្តីខ្លួនក្នុងតំម្លៃ៣០ម៉ឺនបាត និង ៥ម៉ឺន បាតទៀតជាតំម្លៃពលកម្មក្នុងការធ្វើរបង និងសង់ខ្ទមត្រឹមត្រូវ ដោយទទួលលុយកក់មុន ។

នៅថ្ងៃទី១៥-០៧-៩៣ អ្នកទាំង៤ ក្នុងចំណោមអ្នកទាំង៥ ដែលមានឈ្មោះ សៀ ទួច ហាក់ផាត ថាច់រិទ្ធីវុធ និង ណុបរ៉ុន បានយកដីពយម៉ាធូរទី២លក់ទៅឱ្យឈ្មោះ ឆេខា និង ជិនវ៉ាន់ថនម្តងទៀត ដែលជាដីរបស់ឈ្មោះ បជកាន់កាប់តាំងពីឆ្នាំ៩២ រហូតបច្ចុប្បន្ននេះ ។

ដីរបស់ឈ្មោះ លហាឡ គ្មានព្រំប្រទល់ច្បាស់លាស់ ប័ណ្ណកម្មសិទ្ធិចេញមុនថ្ងៃទិញគឺទិញ ថ្ងៃទី២៥-០៧-៩៣ ប័ណ្ណចេញថ្ងៃទី១២-០៧-៩៣ ដូច្នេះសុរិយោដីស្រុកចេញសេចក្តីកែតំម្រូវមួយលុបចោលប័ណ្ណកម្មសិទ្ធិ ព្រោះវាជាន់លើប័ណ្ណកម្មសិទ្ធិរបស់ឈ្មោះបជ។ ដូច្នេះពិនិត្យឃើញថា ប័ណ្ណកម្មសិទ្ធិរបស់ឈ្មោះ លហាឡ ចេញក្រោយបណ្ណ័កម្មសិទ្ធិរបស់ឈ្មោះ ប៉េងជា ហើយការកែតំម្រូវរបស់សុរិយោដីស្រុកនេះ ឈ្មោះ លហាឡ ក៏ពុំបានប្តឹងតវ៉ាដែរ ។ បើពិនិត្យមើលឯកសារលេខ៤៧ ឈ្មោះ ឆេខា និង ជិនវ៉ាន់ថនបញ្ជាក់ថា បានទិញដីទាំងពីរពយនេះស្មើ២៤ហិកតា លក់មួយពយឱ្យលហាឡ ទុកមួយពយលក់ចំណេញថ្ងៃក្រោយ ។ ដីពីរពយមានទំហំ២៤ហិកតាប៉ុណ្ណោះ ដល់លក់មួយពយ ២៤ហិកតា នៅសល់ ២៤ហិកតាទៀត ដល់លហាឡ គាត់ប្តឹង គាត់ទាមទារ៦ហិកតា ៩០អា៤៧សង្ទីអា ដល់ជិន វ៉ាន់ថន និង ឆេខា ធ្វើប្លង់មានប្លង់រហូតដល់២០ប្លង់ក្នុងមួយប្លង់មានដីទំហំ៥ហិកតា ដូច្នេះពិនិត្យឃើញថា ដីរបស់ឈ្មោះ លហាឡ គ្មានទំហំ និងព្រំប្រទល់ច្បាស់លាស់ទេ ។ បើពិនិត្យការវាស់វែង របស់មន្ត្រីកសិកម្ម ចុះថ្ងៃទី១៦-១១-៩៣ គឺធ្វើក្រោយថ្ងៃចេញប័ណ្ណកម្មសិទ្ធិ ចេញប័ណ្ណកម្មសិទ្ធិហើយ ទើបទៅវាស់វែងជាក្រោយ ដូច្នេះ គ្មានការវាស់វែង ពិតប្រាកដទេ ។ ហើយការទិញលក់ រវាងឈ្មោះ ឆេខា និង ជិនវ៉ាន់ថន ឱ្យឈ្មោះ លហាឡ គ្មានឯកសារបញ្ជាក់ច្បាស់លាស់ដែរ ព្រោះ លហាឡ ថាដីមានទំហំ២៤ហិកតា ក្នុងមួយហិកតាស្មើ៣៥.០០០បាត ដូច្នេះ វាស្មើ៨៤ម៉ឺនបាត ហេតុអីក្នុងកិច្ចសន្យាដាក់តម្លៃតែ៧៦ម៉ឺនបាត ។ ឈ្មោះ លហាឡ គាត់ថា ឆេខា និង ជិន វ៉ាន់ថន ជាម្ចាស់ដី តាមពិតអ្នកទាំងពីរនេះគ្មានអ្វីទាល់តែសោះ ដល់គាត់ប្តឹង មកប្តឹងឈ្មោះបជទៅវិញ គាត់គួរតែប្តឹងអ្នកទាំងពីរនោះ ដូច្នេះហើយ ឈ្មោះ លហាឡ ក៏ដកពាក្យបណ្តឹងនោះ ចេញវិញ ហើយតុលាការ ក៏សម្រេចលើកពាក្យបណ្តឹងនេះចេញដែរ ដូច្នេះ ឈ្មោះ លហាឡ គ្មានសិទ្ធិយករឿងដដែលនេះ មកប្តឹង បជទៀតទេ ។ ហើយអ្នកទាំងបួនដែលលក់ដីឱ្យបជហើយ ហើយយកដី ដដែលលក់ឱ្យ ឆេខា និង ជិនវ៉ាន់ថន ទៀតនោះ តុលការក្រុងព្រះសីហនុ បានចេញសាលក្រមព្រហ្មទណ្ឌ ហើយក៏បានអនុវត្តចប់សព្វគ្រប់ហើយដែរ ។

ម្យ៉ាងទៀត ឈ្មោះ លហាឡ គួរតែប្តឹងសុរិយោដីស្រុកដែលចេញប័ណ្ណកម្មសិទ្ធិឱ្យខ្លួន ជាន់កម្មសិទ្ធិអ្នកដទៃ ធ្វើឱ្យខូចប្រយោជន៍របស់ខ្លួន ។ ទីបញ្ចប់ខ្លួនសុំទាមទារ ជម្ងឺចិត្តឱ្យកូនក្តីខ្លួន ពីឈ្មោះ លហាឡ ចំនួន១០ម៉ឺនដុល្លារ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់លោក បជម្ចាស់បណ្តឹងសាទុក្ខ អំណានសារណា ដែលមានម្ចាស់ឈ្មោះ បជនិងនាងចាប គឹមលាង ចុះថ្ងៃទី៣០-០៣-៩៣ និង ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខC1 0132 ដែលមានម្ចាស់ឈ្មោះ ចាប គឹមលាង និងឈ្មោះ បជចុះថ្ងៃទី ៣០-០៣-៩៣ ហើយ ទទួលស្គាល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខC10154,C10156,C10157. C10158, C1 0159 C10160 ចុះថ្ងៃទី១២-០៧-៩៣ នោះគឺជាការខុសឆ្គងយ៉ាងធ្ងន់ធ្ងរ ពីព្រោះថា

+ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីរបស់ បជធ្វើនៅថ្ងៃទី ៣០-០៣-៩៣ ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ឯប័ណ្ណរបស់ លហឡ និងគ្រួសារ ធ្វើក្រោយ៤ខែ១២ថ្ងៃគឺថ្ងៃ១២-០៧-៩៣ ដូច្នេះប័ណ្ណសម្គាល់សិទ្ធិកាន់កាប់របស់បជមិនអាចរំលោភជាន់ទៅលើដីរបស់លហឡ បានឡើយ ។

+របាយការណ៍របស់មេឃុំ បិតត្រាំងលេខ៣៨៩បត ចុះថ្ងៃទី១៦-១១-៩២ ជាគណៈកម្មាធិការវាស់វែងដីម្តុំពយម៉ាចូរ ធ្វើនៅថ្ងៃទី១១-០៧-៩៣ ចុះហត្ថលេខានៅថ្ងៃទី១៦-១១-៩៣ ឯប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ របស់លហឡ និងគ្រួសារ ធ្វើនៅថ្ងៃទី១២-០៧-៩៣ ។ កិច្ចសន្យាទិញលក់រវាងម្ចាស់ដីទាំង ៤ ជាមួយ ធេ ខា ចុះថ្ងៃទី១៥-០៧-៩៣ ,ថ្ងៃទី២៥-០៧-៩៣ ។ ម្យ៉ាងទៀតចម្លើយរបស់ ធេ ខា ថ្ងៃទី១២-០៩-៩៧ក្នុងសំណុំរឿងព្រហ្មទណ្ឌថាទិញដីពីសៀទូចជាង២០ហិកតានៅថ្ងៃ១៦-១០-៨៣ដូច្នេះ បណ្ណ័សម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី របស់លហឡ និងគ្រួសារ ធ្វើមុនកំណត់ហេតុវាស់វែង ទៅដល់អភិបាលស្រុក មុនធេខា ទិញដីពីសៀទូច និងមុនពេល ធេខា លក់ដីឱ្យលហឡ១៧-០៧-៩៣ ,២៨-១០-៩៣ ទៅទៀត ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ទុកជាមោឃៈការជំនុំជំរះរបស់តុលាការព្រហ្មទណ្ឌក្រុងព្រះសីហនុ ហើយមិនលើកយកសាលក្រមព្រហ្មទណ្ឌលេខ០១ ចុះថ្ងៃទី០៥-០១-៩៨ មកពិចារណានោះដោយសំអាងលើមាត្រា២៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនោះ គឺជាការខុសឆ្គងពីព្រោះថា

+ប្រធានស្តីទីសាលាឧទ្ធរណ៍តែម្តង ដែលបានទទួលស្គាល់បញ្ហាបន្ទាន់បង្ខំ ហើយបង្អង់រឿងរដ្ឋប្បវេណី ទុកមួយអន្លើ រង់ចាំស្តាប់រឿងព្រហ្មទណ្ឌតាមចំណារ ចុះថ្ងៃទី២៥-០៩-៩៧ លើពាក្យបណ្តឹង ចុះថ្ងៃទី១៧-០៩-៩៧ របស់បជ។

+ប្រធានស្តីទីសាលាឧទ្ធរណ៍ ដដែលបានបញ្ជាឱ្យធ្វើលិខិត សួរទៅតុលាការក្រុងព្រះសីហនុ តើរឿង ព្រហ្មទណ្ឌនោះ ដល់ណាហើយ តាមចំណារ ចុះថ្ងៃទី២៧-១១-៩៧ ។

+នៅថ្ងៃទី០៩-០៧-៩៨ សាលាឧទ្ធរណ៍បានចេញសាលដីការបៀបលេខ៣២ បញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ៨០ ចុះថ្ងៃទី១២-០៩-៩៧ របស់តុលាការក្រុងព្រះសីហនុមកក្នុងសំណុំរឿងលេខ៤០ ចុះ

ថ្ងៃទី២៧-១០-៩៧ របស់ សាលាឧទ្ធរណ៍ដោយសំអាងហេតុថារឿងព្រហ្មទណ្ឌលេខ៨០ចុះថ្ងៃទី១២-០៩-៩៧ មានទាក់ទិននឹងសំណុំរឿងលេខ៤០ ។

-យលឃើញថា លហាឡ គ្មានលក្ខណៈសម្បត្តិ និង ប្តឹងទារដីពីបជឡើយ ពីព្រោះថា +កម្មវត្ថុបណ្តឹង ជាវត្ថុដដែល លក់ឱ្យច្រើននាក់តៗគ្នា បជគ្មានជាប់ទាក់ទងក្នុងការទិញលក់ដី ជាមួយលហាឡ ទេគឺឆេ ខា ទេ ដែលជាអ្នកលក់ដីឱ្យលហាឡ ម្យ៉ាងទៀត លហាឡ ក៏បានយក ដីនេះលក់បន្តទៅឱ្យអ្នកដទៃទៀតទៅហើយ ។

-យល់ឃើញថា បជពិតជាបានទិញដីពយម៉ាចូវ ទាំងពីរពយពីសៀ ទូច ហៅ សំសារិន ដែលជាតំណាងឱ្យហាក់ ផាត ថាច់ រិទ្ធីវុធ និងលោក ណុប រ៉ុន ពិតប្រាកដមែន ហើយអ្នកទាំង៤នេះ នៅតែទទួលស្គាល់ការ លក់ទិញនេះជានិច្ច ។

-យល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ៨០ ចុះថ្ងៃទី១២-០៨-៩៧ របស់តុលាការក្រុងព្រះសីហនុបានចូលជាស្ថាពរ

-យល់ឃើញថា លោក លហាឡ និងមេធាវីរបស់លោកបានធ្វើសារណាការពាររឿងក្តីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែមិនបានមកចូលរួមនាពេលសវនាការនេះទេ ដូច្នេះ តុលាការកំពូលជំនុំជំរះកំបាំងមុខ លោកប៉ុន្តែ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា ការដែលមេធាវី ម្ចាស់បណ្តឹងសាទុក្ខសុំទារសំណងជម្ងឺចិត្ត១០ម៉ឺនដុល្លារអាមេរិកនោះ តុលាការកំពូលពុំយកមកពិចារណាឡើយ ដោយសាម៉ីខ្លួនពុំបានប្តឹងសុំពីសាលាជាន់ក្រោមមក ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤០៤ ចុះថ្ងៃទី១៦-០៧-៩៨ របស់សាលាឧទ្ធរណ៍ដែលបាន សម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

ចំពោះមុខលោក បជកំបាំងមុខលោក លហាឡ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៣៣៣ ចុះថ្ងៃទី៣១-០៨-៩៨ របស់លោក បជទុកជាត្រឹមត្រូវ ទាំងទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ៤០៤ ចុះថ្ងៃទី១៦-០៧-៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-ទទួលស្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី របស់ឈ្មោះ បជនិងនាង ចាប គឹមលាង លើដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លេខC10132 ចុះថ្ងៃទី៣០-០៣-៩៣ និងលេខC10133ចុះថ្ងៃទី៣០-

០៣-៩៣ ដែលមានទីតាំងលើពយម៉ាចូវទាំងពីរ នៅក្នុងភូមិគគីរឃុំបិត ស្រុកព្រៃនប់ ក្រុងព្រះសីហនុ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកបជបានបង់ទុកនៅតុលាការកំពូលចំនួន១៩០០០រៀល គឺពន្ធ ចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែ ប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវឱ្យលោក លហាឡ សងប្រាក់ចំនួន១៩០០០រៀល ទៅលោក ប៉េង ជាវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ ។